កម្ពុជាបច្ចុប្បន្ន

KAMPUCHEA TODAY

កម្ពុជាបច្ចុប្បន្ន

KAMPUCHEA TODAY

KAMPUCHEA TODAY,

Photos : Tien–Thoeung–Kosal — Sam El–Phal Kun–Serei Vuth.
Documentary photos: SPK–VNA–Pracheachon News–Kampuchea News
– Trade Union — Youth Association
– Ministry of Foreign Affairs–Cabinet of C.C of P.R.P.K
Text : Yok Kun–Yi Thon
Kampuchea Life and developments
© Ministry of Information and Culture Phnom Penh. 1988 P.R.K

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី ១០
ទិវាបុណ្យជាតិ ៧ មករា

IN HONOUR OF THE 10th NATIONAL DAY OF 7th JANUARY.

កម្ពុជាបច្ចុប្បន្ន

KAMPUCHEA TODAY

ការផ្សាយរបស់ក្រសួង ឃោសនាការ និង វប្បធម៌ ភ្នំពេញ ១៩៨៨

A publication of the Ministry of Information and Culture
Phnom Penh 1988.

សញ្ញាជាតិ

នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

NATIONAL EMBLEM

សញ្ញាជាតិ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាងមូល ផ្ទៃក្រហម មានកម្រងកួរស្រូវពណ៌មាសអមសងខាងជារង្វង់ ស្នែងក្របីផ្គួបគ្នាខាងចុង ខ្សែបូក្រហមរុំព័ទ្ធផ្នែកខាងក្រោម នៃ កម្រងកួរស្រូវជាពីរថ្នាក់ ។ នៅកណ្តាលខ្សែបូ មានចារឹកអក្សរ មាសថា : សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

សៀវភៅមាសរដ្ឋធម្មនុញ្ញបើកទំព័រតម្កល់លើដើមស្រូវចងជាបូ។ កង់គ្រឿងចក្រចេញរាងពាក់កណ្តាលមានកាំ ៧ ផ្នែកពីមុខ សៀវភៅមាស ។

នៅលើកង់គ្រឿងចក្រ រូបប្រាសាទអង្គរវត្តកំពូល ៥ ពណ៌មាស ស្ថិតនៅចំរង្វង់កម្រងកួរស្រូវ ។

Base : An open Book Containing the Constitution of P.R.K.

Lower motif : Wheel symbolising industry, the 7 cops representing 7th January.

Upper motif : 5 towers of Angkor Wat.

Surround : Rice Symbolising Agriculture.

On the red Ribbon : The people's Republic of Kampuchea

ទង់ជាតិ

NATIONAL FLAG

ទង់ជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានរាងចតុកោណកែង ពណ៌ក្រហម ចំកណ្តាលផ្ទៃមានប្រាសាទអង្គរវត្តកំពូលប្រាំពណ៌មាស

The flag of the People's Republic of Kampuchea has the golden five towers of Angkor Wat in the middle of a red rectangle.

ភ្លេងជាតិ

NATIONAL ANTHEM

THAILAND
PEOPLE'S DEMOCRATIC REPUBLIC OF LAO
PREAH VIHEA
SIEM REAP OUDOR MEAN CHEY
BANTEAY MEAN CHEY
STUNG TRENG
RATTANAKIRI
BATTAMBANG
KG THOM
MONDOL KIRI
KRATIE
PURSAT
KG CHHNANG
KG CHAM
KOH KONG
KG SPOEU
PHNOM PENH
PREY VENG
KANDAL
TAKEO
SVAY RIENG
KOMPOT
KOMPONG SOM
GULF OF SIAM
SOCIALIST REPUBLIC OF VIETNAM

សមមិត្ត ហេង សំរិន
អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍កម្ពុជា
ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

Comrade HENG SAMRIN Secretary General
of the Central Committee of the People's Revolutionary Party of Kampuchea,
President of the State Council of the People's Republic of Kampuchea.

កម្ពុជាបច្ចុប្បន្ន

សាធារណរដ្ឋប្រជាមានិតកម្ពុជា ជារដ្ឋមួយស្ថិតនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ និង នៅភាគខាងត្បូងនៃឥណ្ឌូចិន ។ រដ្ឋនេះមានផ្ទៃក្រឡាចំនួន ១៨១.០៣៥ គ.ម² និងមានប្រជាជន ជិត ៧.៩០០.០០០ នាក់ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជា មាន ២១ ខេត្ត ក្រុងគឺ ៖ រដ្ឋធានីភ្នំពេញ ក្រុងកំពង់សោម កណ្ដាល ព្រៃវែង ស្វាយរៀង តាកែវ កំពត កោះកុង កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប-ឧត្ដរមានជ័យ ព្រះវិហារ កំពង់ធំ កំពង់ចាម ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ។ ភ្នំពេញជារដ្ឋធានីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ក្រុងកំពង់សោមជាកំពង់ផែសមុទ្រ ទឹកជ្រៅរបស់ប្រទេស ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា មានព្រំប្រទល់ខាងជើងទល់នឹងរាជាណាចក្រថៃ និង សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខាងកើតទល់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងត្បូងទល់នឹង សាធារណរដ្ឋសង្គមនិយមវៀតណាម និងឈូងសមុទ្រថៃ ខាងលិចទល់នឹងរាជាណាចក្រថៃ ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាប្រទេសមួយសម្បូរទៅដោយភោគទ្រព្យធម្មជាតិនិងមានខឿនសិល្បៈវប្បធម៌រុងរឿងតាំងពីរាប់ពាន់ឆ្នាំ ។ ស្ថានភាពនៃប្រទេសអាចចែកចេញជាបីតំបន់ដាច់ពីគ្នាយ៉ាងច្បាស់លាស់គឺ ៖ តំបន់ជួរភ្នំ-តំបន់វាលរាបនិងតំបន់ខ្ពង់រាប ។ តំបន់ជួរភ្នំលាតសន្ធឹងជាកំពែងតាមបណ្ដោយព្រំដែន កម្ពុជា ថៃ ពីទិសខាងជើងរហូតដល់ទិសខាងលិច ។ កំពូលខ្ពស់បំផុតនៃជួរភ្នំនេះ គឺភ្នំឱរ៉ាល់ ដែលមានកំពស់ ១៨០០ ម៉ែត្រ ធៀបនឹងផ្ទៃទឹកសមុទ្រ ។ តំបន់ជួរភ្នំជាតំបន់សម្បូរព្រៃឈើ និងសត្វម្រឹគ ។ ស្ទឹង ជ្រោះជាច្រើនបានចាប់ប្រភពពីលើកំពូលជួរភ្នំនោះ ហើយហូរចុះមកតំបន់វាលរាប និងហូរចុះទៅឈូងសមុទ្រថៃ ។

តំបន់ខ្ពង់រាបស្ថិតនៅភាគឦសាននៃប្រទេស ចាប់ពីព្រំប្រទល់នៃប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ ចុះទៅខាងត្បូងតាមបណ្ដោយច្រាំងខាងកើតនៃទន្លេមេគង្គ ។ ភាគច្រើននៃតំបន់នេះជាតំបន់ដីក្រហមកំអែភ្នំភ្លើងដ៏មានជីជាតិ ។ ដំណាំឧស្សាហកម្មដូចជា កៅស៊ូ កាហ្វេ ដំណាំហូបផ្លែ និងព្រៃឈើដុះលូតលាស់ល្អណាស់នៅតំបន់នេះ ។

តំបន់វាលរាបស្ថិតនៅចំកណ្ដាលផ្ទៃប្រទេស ហើយលាតសន្ធឹងពីជើងភ្នំដងរែក នៅភាគពាយ័ព្យនៃប្រទេស ទៅទល់នឹងព្រំដែន កម្ពុជា - វៀតណាម នៅភាគអាគ្នេយ៍នៃប្រទេស ។ តំបន់វាលរាបជាប្រភពផ្ដល់ស្បៀងអាហារសំរាប់ចិញ្ចឹមប្រជាជនកម្ពុជាទូទាំងប្រទេស ដោយមកពីតំបន់នេះសម្បូរទៅដោយវាលស្រែមានជីជាតិល្អ មានទន្លេ ស្ទឹង បឹងបួផ្ដល់ទឹកទាំងប្រាំងវស្សា ។ បឹងទន្លេសាបគឺជាជម្រកត្រីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ មេគង្គប្រភពទឹកមិនរីងស្ងួតជាទន្លេសំខាន់បំផុតដែលហូរស្រោចស្រពប្រទេសកម្ពុជា ពីព្រំដែនខាងជើងដល់ខាងត្បូងប្រកបដោយដីល្បប់ដ៏មានជីជាតិ និងមច្ឆជាតិដ៏មានឧជារស ។

ប្រជាជនកម្ពុជាដ៏ឧស្សាហ៍ព្យាយាម និងអង់អាចក្លាហានរួមជាង ៣០ ជនជាតិបានរស់នៅលើទឹកដីដ៏ប្រសិទ្ធិនេះតាំងពីច្រើនសតវត្សមកហើយ ។ ក្នុងប្រវត្តិសាស្ត្រដ៏យូរលង់នៃអត្ថិភាពរបស់ខ្លួន ប្រជាជនកម្ពុជាបានតស៊ូយ៉ាងប្តូរផ្តាច់ប្រឆាំងសង្គ្រាមឈ្លានពានពីខាងក្រៅ ដើម្បីការពារបូរណភាពទឹកដី និងកសាងមាតុភូមិជាទីស្នេហារបស់ខ្លួន ។

ពីសតវត្សទី ៩ គ.ស ដល់សតវត្សទី ១៤ គ.ស ប្រជាជនកម្ពុជាបង្កើតបាននូវអរិយធម៌មួយដ៏ល្បីល្បាញនិងជាទីមោទនៈនៃមនុស្សជាតិផងដែលសកលលោកធ្លាប់ហៅថាអរិយធម៌អង្គរ ។

សក្ខីភាពនៃសម័យមហានគរដ៏រុងរឿងនោះ គឺប្រាសាទបុរាណរាប់ពាន់ ប្រកបដោយក្បូរក្បាច់រចនាល្អគ្មានពីរដែលមាននៅពាសពេញទូទាំងប្រទេសរហូតដល់សព្វថ្ងៃ ។

ប្រាសាទអង្គរវត្ត និង ប្រាសាទបាយ័ន្ត ដែលជានិមិត្តរូបនៃទេពកោសល្យ ច្នៃប្រឌិតនៃសិល្បករខ្មែរ សព្វថ្ងៃនៅតែរក្សាបាននូវសម្រស់ដ៏ល្អឥតខ្ចោះទាំងខាងស្ថាបត្យកម្ម ទាំងខាងសិល្បៈតុបតែង ដែលមនុស្សលោកស្ទើរតែពុំអាចជឿបានថាមនុស្សអាចធ្វើបាននូវអច្ឆរិយវត្ថុយ៉ាងដូច្នេះ ។

ប៉ុន្តែដោយសារមហិច្ឆតាល្មោភអំណាច ល្មោភសង្គ្រាម ដោយសារអំនួតនិងការភ្លើតភ្លើនភ្លេចខ្លួនរបស់ពួកសក្តិភូមិមើលស្រាលចំពោះខ្មាំងសត្រូវ អរិយធម៌ដ៏រុងរឿងនោះក៏ធ្លាក់ចុះបន្តិចម្តង ៗ ចាប់តាំងពីចុងសតវត្សទី ១៤ រហូតដល់ស្ទើរតែរលាយសាបសូន្យ ។ នៅក្នុងរយៈកាលជិត ៦០០ ឆ្នាំ ប្រជាជនកម្ពុជាស្គាល់តែសេចក្តីទុក្ខសោក វិនាសប្រាសព្រាត់ និងភាពអន្តរាយ ហិនហោចឥតមានល្ហែ ដោយសារតែចម្បាំងដណ្តើមរាជ្យ រវាងបងប្អូនឯងរបស់ពួកសក្តិភូមិ ។

ការបាក់បែកសាមគ្គីផ្ទៃក្នុងនេះធ្វើអោយស្ថានភាពរបស់ប្រទេសចុះដុនដាប រហូតដល់ធ្លាក់ទៅក្នុងក្រញាំនៃពួកអាណានិគមនិងចក្រពត្តិនិយមផ្លាស់ប្តូរគ្នាដាក់នឹមត្រួតត្រា បន្តបន្ទាប់គ្នាអស់រាប់រយឆ្នាំ ។

រយៈពេលរាប់រយឆ្នាំនៃការជិះជាន់កេងប្រវ័ញ្ចរបស់ពួកអាណានិគមបរទេស គឺជារយៈកាលនៃការតស៊ូ ដ៏ចំរះរបស់ប្រជាជនដែលបានក្រោកឈរបន្តបន្ទាប់គ្នាប្រយុទ្ធយ៉ាងអង់អាចក្លាហានដើម្បីដណ្តើមមកវិញនូវសិទ្ធិសេរីភាព និង ឯករាជ្យដែលបាត់បង់ទៅ ។

ថ្ងៃ ១៧ មេសា ១៩៧៥ ប្រជាជនកម្ពុជាបានវាយកម្ទេចរបបសាធារណរដ្ឋខ្មែរ ដែលចក្រពត្តិអាមេរិកបានបង្កើតឡើង ។ ប្រជាជនកម្ពុជាគ្រប់ ៗ រូបនរណាក៏នឹកសង្ឃឹមថានឹងបានរស់នៅសុខសន្តិភាព មានសិទ្ធិសេរីភាព មានសុភមង្គល និងប្រកបការងាររួមចំណែក ជួសជុលស្លាកស្នាមដែលសង្គ្រាមបំផ្លិចបំផ្លាញបានបន្សល់ទុកយ៉ាងធ្ងន់ធ្ងរ ។

ប៉ុន្តែសេចក្តីសង្ឃឹមទាំងប៉ុន្មានបានរលាយខ្យល់ទៅវិញតែក្នុងប៉ុន្មាននាទីក្រោយមក ។ ពួកឧកាសនិយម ប៉ុល ពត អៀង សារី ខៀវសំផន បានកេងប្រវ័ញ្ចយកជ័យជំនះ ដែលបដិវត្តន៍កម្ពុជាដណ្តើមបានយកជាសម្បត្តិផ្ទាល់ខ្លួនវា ។ ពួកវាបានប្រែក្លាយ ប្រទេសកម្ពុជា ដែលទ្រុឌទ្រោមដោយសង្គ្រាមស្រាប់អោយកាន់តែវិនាស ហិនហោចថែមទៀត ។ ប្រជាជនកម្ពុជាទូទាំងប្រទេសក្លាយទៅជាទាសករ ជាអ្នកទោសអស់ជីវិត ។ រចនាសម្ព័ន្ធចាត់តាំង បរិក្ខាសង្ហារណរបស់សង្គមទាំងមូលត្រូវពួកវាបំផ្លាញកម្ទេចចោលទាំងស្រុង ។ គ្រាន់តែមួយប៉ប្រិចភ្នែក សមិទ្ធិកម្មដែលប្រជាជនកម្ពុជាបានខិតខំកសាងរាប់រយរាប់ពាន់ឆ្នាំត្រូវបំផ្លាញគ្មានសល់ ។ សាលារៀន ទីផ្សារ ប្រាក់ចាយ សាសនា វត្តអារាម មន្ទីរពេទ្យ រោងចក្រសហគ្រាស ទីក្រុង ត្រូវលុបបំបាត់ចោលទាំងស្រុង ។ ពួកប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ខៀវសំផន បានរុញច្រានប្រជាជនកម្ពុជាធ្លាក់ទៅក្នុងជ្រោះប្រល័យពូជសាសន៍យ៉ាងសាហាវព្រៃផ្សៃ ដែលគេមិនដែលបានជួបប្រទះសោះ នៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ។ កម្ពុជាទាំងមូលបានក្លាយជាកន្លែងធ្វើមនុស្សឃាត គួរអោយព្រឺខ្លាច ។ គ្រាន់តែក្នុងរយៈ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ពួកវាសម្លាប់មនុស្សឥតរើសមុខអស់ជាង៣ លាននាក់ ។បញ្ញវន្ត គ្រូពេទ្យ វិស្វករ សិល្បករ សាស្ត្រាចារ្យ គ្រូបង្រៀន កម្មករបច្ចេកទេស ប្រហែល ៩០ ភាគរយត្រូវពួកវាសម្លាប់ទាំងគ្រួសារ។

សិល្បៈវប្បធម៌ អក្សរសាស្ត្រ ដែលជាព្រលឹងជាតិ គម្ពីរដីកា ក្បួនខ្នាត ប្រាសាទបុរាណ រូបចម្លាក់ រាប់រយរាប់ពាន់ ក៏ត្រូវពួកវាបំផ្លាញចោលដែរ ។

ដោយឃើញមហន្តរាយនៃការសាបសូន្យពូជសាសន៍ ចូលមកដល់ ជនស្នេហាជាតិបរិសុទ្ធដែលបានគេចផុតពីការកាប់សម្លាប់និងពីពន្ធនាគារឥតជញ្ជាំងបាន ប្រមូលផ្តុំគ្នាក្រោកឈរបង្កើតបានរណសិរ្សមួយដែលមានឈ្មោះរណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជា នៅថ្ងៃ ០២ ខែ ធ្នូ ១៩៧៨ ដើម្បីរំដោះ

ប្រទេសឲ្យរួចពីគ្រោះប្រល័យពូជសាសន៍ ។ ក្រោមការដឹកនាំត្រឹមត្រូវរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងដោយបានការជួយឧបត្ថម្ភគាំទ្រយ៉ាងស្មោះស្ម័គ្រ និងទាន់ពេលវេលាពីបក្ស ប្រជាជន និងកងទ័ពស្ម័គ្រចិត្តវៀតណាម ប្រជាជនកម្ពុជា ទូទាំងប្រទេសបានតស៊ូប្រយុទ្ធព្រមគ្នា ផ្ដួលរំលំពួកដៃគ្នារាយរបប ប៉ុល ពត អៀង សារី ខៀវ សំផន រលំរលាយ វិនាសខ្ទាត់ខ្ទាយ ហើយរំដោះបានជ័យជំនះទាំងស្រុងនៅថ្ងៃទី ០៧-០១-១៩៧៩ ។

០៧-០១-១៩៧៩ ជាទិវាប្រវត្តិសាស្ត្រដែលប្រជាជនកម្ពុជាគ្រប់រូបចងចាំពុំអាចបំភ្លេចបាន ។ ប្រជាជនកម្ពុជាគ្រប់រូបចាត់ទុកថាថ្ងៃ ០៧-០១-១៩៧៩ ជាថ្ងៃកំណើតទី ២ របស់ខ្លួន ។

រាត្រីដ៏ខ្មៅងងឹតនៃគ្រោះប្រល័យពូជសាសន៍បានកន្លងផុតទៅ ដោយនាំយកទាំងពួកព្រាយបិសាចស្រេកឈាមទៅផងមួយផង ។ ពន្លឺព្រះអាទិត្យនៃទិវាថ្មីបានរះឡើងយ៉ាងត្រចះត្រចង់នៅលើទឹកដីអង្គរដ៏ទីស្នេហាសាជាថ្មី សេចក្ដីសង្ឃឹមបានមកស្ថិតនៅក្នុងបេះដូងរបស់ប្រជាជនកម្ពុជា គ្រប់រូបឡើងវិញ ។

ប៉ុន្តែផលវិបាកនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដ៏អាស្រូវ បានបន្សល់ទុកយ៉ាងធ្ងន់ធ្ងរ លើគ្រប់វិស័យឲ្យរដ្ឋអំណាចបដិវត្តយើង ។ ទន្ទឹមនឹងជ័យជំនះរំដោះបាន ប្រជាជនយើងគ្រប់រូបក៏ត្រូវប្រឈមមុខដោះស្រាយបញ្ហារាប់រយជំពូកដែរ ។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ទោះបីម្នាក់ៗសុទ្ធតែបាក់កម្លាំង សុទ្ធតែពិការខាងផ្លូវចិត្ត សុទ្ធតែមានជំងឺប្រចាំកាយ ទោះគេមានតែបាតដៃទទេក៏ដោយតែម្នាក់ៗសុទ្ធតែបានរួមចំណែកយ៉ាងសកម្មការពារជ័យផលបដិវត្ត ការពារខឿនគោករាជ្យជាតិ និងរួមចំណែកកសាងប្រទេសឡើងវិញ ។ គ្រប់ផ្នែកគ្រប់វិស័យនៃរចនាសម្ព័ន្ធសង្គមទាំងមូល សុទ្ធតែត្រូវចាប់ផ្ដើមដំណើរការកសាងពីលេខសូន្យឡើងវិញដូចគ្នា ។

បក្សប្រជាជនបដិវត្តកម្ពុជា ដែលជាបក្សស្មោះត្រង់ និងលទ្ធិម៉ាក្សលេនីនដ៏បរិសុទ្ធ ត្រូវបានកសាងឡើងវិញជាបន្ទាន់ ។ ចំណងមិត្តភាព សាមគ្គីភាពកម្ពុជា វៀតណាម ឡាវ និងបណ្ដាប្រទេសសង្គមនិយមជាបងប្អូនបានត្រូវពង្រឹងនិងពង្រីកឥតឈប់ឈរ ។

នៅក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងភ្លឺស្វាងរបស់បក្សប្រជាជនបដិវត្តកម្ពុជាតួបផ្សំ និងការជួយឧបត្ថម្ភអស់ពីចិត្តពីថ្លើមរបស់បណ្ដាប្រទេសសង្គមនិយមជាបងប្អូនជាអាទិមាន សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និង ប្រទេសសង្គមនិយមជាបងប្អូនផ្សេងទៀត ព្រមទាំងអង្គការមនុស្សធម៌ អន្តរជាតិដទៃទៀតគ្រប់ផ្នែកគ្រប់វិស័យត្រូវបានស្ដារឡើងវិញនិងមានការរីកចំរើនយ៉ាងឆាប់រហ័សគួរជាទីមោទនៈ។ ផ្អែកលើការប្រែប្រួលយ៉ាងឆាប់រហ័សទាំងខាងនយោបាយ សេដ្ឋកិច្ចទាំងការទូត មហាសន្និបាតតំណាងបក្សទូទាំងប្រទេសលើកទី៥ បានកំណត់នូវភារកិច្ច និងគោលដៅថ្មីរបស់បដិវត្តកម្ពុជាដែលជារបត់ផ្លូវថ្មីមួយឈានទៅរកការរីកចំរើនថ្មី ដើម្បីត្រៀមលក្ខណៈឆ្លងអន្តរកាលឆ្ពោះឈានឡើងសង្គមនិយម ។

នៅក្នុងរយៈកាល ១០ ឆ្នាំ កន្លងទៅ រដ្ឋអំណាចបដិវត្តកម្ពុជា មិនគ្រាន់តែបានកាន់កាប់ទាំងស្រុង បូរណភាពទឹកដីកម្ពុជាទេ តែនៅបានកសាងនិងពង្រឹងរដ្ឋអំណាចមូលដ្ឋានកាន់តែរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃថែមទៀត ។

គ្រប់ស្ថាប័នរដ្ឋបានដំណើរការដូចប្រក្រតី និងមានការរីកចំរើនគ្រប់ផ្នែក ។

កម្មករ កសិករ បុគ្គលិក កម្មាភិបាល មានសាមគ្គីឯកភាពជុំវិញបក្សបានបំពេញភារកិច្ចរៀងៗ ខ្លួនយ៉ាងសកម្មប្រយុទ្ធ ។

លទ្ធផលនៃការខិតខំប្រឹងប្រែងយ៉ាងព្រះពោរនេះ ក៏បានលេចចេញជាសមិទ្ធិផលគួរឲ្យស្ញើចសរសើរ ។

ផ្ទៃដីដាំដុះត្រូវបានស្ដារពង្រីកពី ៨០០.០០០ ហិកតា នៅឆ្នាំ ១៩៧៩ ទៅជាង ២.០០០.០០០ ហិកតា នៅឆ្នាំ ១៩៨៨ ។ ក្រៅពីដំណាំស្រូវ រដ្ឋបានយកចិត្តទុកដាក់ជំរុញយ៉ាងខ្លាំងក្លាការចិញ្ចឹមសត្វ និង ដំណាំរួមផ្សំនានាដូចជា ពោត សណ្ដែក ល្ង ម្រេច និងដំណាំឧស្សាហកម្មផ្សេងទៀត ថ្នាំជក់ ក្រចៅ កប្បាស ។ល។

ដំណាំកៅស៊ូជាមុខព្រួញសេដ្ឋកិច្ចសំខាន់មួយរបស់រដ្ឋ។ យើងបានស្តារអាជីវកម្មកៅស៊ូមានស្រាប់ ពី ៥.០០០ ហិកតា នៅក្នុងឆ្នាំ ១៩៨០ ទៅដល់ ៤៣.០០០ ហិកតា នៅឆ្នាំ ១៩៨៨ ។ ការផលិតជ័រស្ងួតបានកើតពី ១.៣០០ តោន នៅឆ្នាំ ១៩៨០ ទៅដល់ ២៤.៩០០តោន នៅឆ្នាំ ១៩៨៨ ។

ខាងផ្នែកអាជីវកម្មព្រៃឈើ ដែលជាមុខសញ្ញាសំខាន់មួយទៀតរបស់សេដ្ឋកិច្ចរដ្ឋ ក៏មានការរីកចំរើនគួរអោយកត់សំគាល់ ។ ពីឆ្នាំ ១៩៨០ យើងផលិតឈើបានតែ ៧០០ម៉ែត្រគីបទេ ប៉ុន្តែដល់ចុងឆ្នាំ ១៩៨៧ យើងផលិតបាន ១៥៧.៤៤១ ម៉ែត្រគីប ។ ទន្ទឹមនឹងការធ្វើអាជីវកម្មកាប់ឈើរដ្ឋបានយកចិត្តទុកដាក់ចាត់តាំងការថែរក្សាព្រៃឈើដែលមានស្រាប់ និងដាំឈើ កូនឈើយ៉ាងសកម្ម ។ នៅឆ្នាំ ១៩៨៨ យើងដាំបាន ៦៥០ ហិកតា ។

ផលផលជាមុខព្រួញសេដ្ឋកិច្ចដែលបក្ស និងរដ្ឋយកចិត្តទុកដាក់ជំរុញយ៉ាងខ្លាំងក្លា ។ នៅក្នុងឆ្នាំ ១៩៨០ ផលិតផលនេសាទទឹកសាបមាន ១៨.៤០០ តោន តែដល់ឆ្នាំ ១៩៨៧ ផលិតផលនេសាទទឹកសាបបានកើតដល់ ៦២.១៥៤ តោន។ រីឯផលិតផលសមុទ្រវិញបានកើតពី ១.២០០ តោន នៅឆ្នាំ ១៩៨០ ទៅដល់ ៩.៨៨៤ តោន នៅចុងឆ្នាំ ១៩៨៧ ។ ចំពោះវិស័យឧស្សាហកម្មសិប្បកម្ម យើងបានជួសជុល និងស្តារឡើងវិញ រោងចក្រ តូច ធំ ដែលខូចខាតដោយសារសង្គ្រាម ឲ្យដំណើរការឡើងវិញស្ទើរតែទាំងអស់ ។ នាបច្ចុប្បន្ននេះរដ្ឋមានរោងចក្រជាង ៥០ ដែលបានដំណើរការជាធម្មតា ។ ក្រៅពីនេះ នៅមានរោងសិប្បកម្មធុនតូចជាង ១ ពាន់កន្លែង ដែលក្រុមសាមគ្គីសមូហភាពបានបង្កើតឡើងដើម្បីផលិតវត្ថុប្រើប្រាស់ និងឧបករណ៍ផលិតកម្មផ្សេងៗ រួមចំណែកដោះស្រាយសេចក្តីត្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ផ្លូវគមនាគមន៍ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវដែក និង ផ្លូវអាកាស ត្រូវបានដំណើរការយ៉ាងមមាញឹក ក្នុងការដឹកជញ្ជូនអ្នកដំណើរនិងបំរើឲ្យចរាចរទំនិញ បំរើប្រជាជននៅគ្រប់ជនបទគ្រប់ច្រកល្ហកដាច់ស្រយាលក្នុងទូទាំងប្រទេស ។ ផែសមុទ្រក្រុងកំពង់សោម ដែលនៅក្នុងរបប ប៉ុលពត ទទួលតែកប៉ាល់មកពីបេកាំង ឥឡូវបានបើកទ្វារទទួលកប៉ាល់សមុទ្រមកពីគ្រប់ប្រទេសឲ្យចូលចតជារៀងរាល់ថ្ងៃ ។ ផ្លូវអាកាស ដែលកាលពីក្នុងរបបប្រល័យពូជសាសន៍ មានផ្លូវហោះហើរតែមួយគត់គឺ ផ្លូវភ្នំពេញ-បេកាំង ឥឡូវអាកាសយានដ្ឋានអន្តរជាតិ ពោធិចិនតុង បានតភ្ជាប់ផ្លូវអាកាសជាមួយប្រទេសសង្គមនិយមជាបងប្អូន ។

ផ្លូវដែកភ្នំពេញ កំពង់សោម ភ្នំពេញ បាត់ដំបង កំពុងធ្វើចរាចរយ៉ាងមមាញឹក ។ ផ្លូវដែកទាំងពីរខ្សែនេះបានដឹកជញ្ជូនទំនិញរាប់ពាន់តោនក្នុងមួយថ្ងៃៗ ។

ថ្មីៗនេះ យើងទើបដាក់ឲ្យដំណើរការនូវស្ថានីយ៍ផ្កាយរណប “បាយ័ន” ដែលជាសំណង់មិត្តភាពកម្ពុជា សូវៀត ។ ស្ថានីយ៍ផ្កាយរណបនេះផ្តល់លទ្ធភាពឲ្យប្រជាជនយើង អាចធ្វើទំនាក់ទំនងតាមទូរស័ព្ទបានជាមួយ គ្រប់ប្រទេស នៅលើសកលលោក ។

វិស័យអប់រំដែលត្រូវលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ខៀវ សំផន នោះត្រូវបានស្តារឡើងវិញយ៉ាងរហ័ស។ ការបើកបវេសនកាលទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៤ កញ្ញា ១៩៧៩ ជាប្រវត្តិសាស្ត្រក្រោមអធិបតីភាពសមមិត្តហេង សំរិន ។ យើងកសាងបានប្រព័ន្ធអប់រំថ្មីមួយ ដែលមានចាប់ពីមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និង សិក្សាឯកទេស។ មកដល់ឆ្នាំសិក្សា១៩៨៧-១៩៨៨ យើងមានសិស្សានុសិស្សនិស្សិត ១.៧០០.០០០ នាក់ បានចូលរៀនគ្រប់ភូមិសិក្សា ក្នុងនោះមានកុមារតូចៗចំនួន ៥៩.៦២១ នាក់ ចូលរៀននៅសាលាមត្តេយ្យ ។ ក្នុងឆ្នាំកន្លងទៅមានមនុស្សចំនួន ១.០០២.២២៨ នាក់ត្រូវបានរួចផុតពីគ្រោះមិនចេះអក្សរ ។ សិស្សថ្នាក់បំពេញវិជ្ជាបានកើនដល់ ១៨៣.៩៩៤ នាក់។ជារៀងរាល់ឆ្នាំមានសិស្សនិស្សិតជាង ១.០០០ នាក់ ត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលឯបរទេស។ មកដល់បច្ចុប្បន្ននេះយើងមានគ្រឹះស្ថានឧត្តមសិក្សាចំនួន ៦ ដែលមានមុខឯកទេសចំនួន ៣០ ។ គ្រឹះស្ថានមធ្យមសិក្សាឯកទេសចំនួន ២៦ ដែលមានមុខឯកទេសចំនួន

៦១ និង សាលាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២៩ ដែលមានមុខជំនាញចំនួន ៣៧ ។ បុគ្គលិកសិក្សាសរុបទូទាំងប្រទេសមានជាង ៧៧.០០០នាក់ ។

វិស័យសិល្បៈវប្បធម៌ ការថែរក្សាសម្បត្តិវប្បធម៌ជាតិ ការគ្រប់គ្រងសិល្បករ និង ការបណ្តុះបណ្តាលស្រាវជ្រាវ ក៏មានសន្ទុះរីកចំរើនគួរឲ្យចាប់អារម្មណ៍ ។ ក្នុងរយៈពេល ១០ឆ្នាំ យើងបង្កើតបានក្រុមសិល្បៈអាជីពចំនួន ៤២ ក្រុម ក្រុមសិល្បៈមហាជនចំនួន ២.៩៥០ ក្រុម ។ យើងមានសិល្បករអាជីព ១.២៦០ នាក់ ។ យើងកសាងបានរោងមហោស្រពធំ ៗ នៅគ្រប់ខេត្ត ក្រុង ។ ភាពយន្តជាសិល្បៈដែលមហាជនចូលចិត្តជាងគេនោះ បញ្ចាំងជាអចិន្ត្រៃយ៍ និងក្រុមភាពយន្តចល័តត្រូវបានចាត់តាំងបញ្ចាំងនៅគ្រប់ច្រកល្ហកដាច់ស្រយាលក្នុងទូទាំងប្រទេស ។ ទន្ទឹមនឹងការនាំចូលខ្សែភាពយន្តពីបរទេស យើងបាននិងកំពុងខិតខំផលិតខ្សែភាពយន្តរឿងដោយខ្លួនយើង ។ សាលាវិចិត្រសិល្បៈ សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា បានបណ្តុះបណ្តាលចាប់ពីបឋម មធ្យម និងឈានទៅបណ្តុះបណ្តាលផ្នែកឧត្តមខាងសិល្បៈវប្បធម៌ និង កីឡា ។

យើងបានចាត់តាំងជាថ្មីនូវគណៈកម្មាធិការជាតិអូឡាំពិកខ្មែរ ដែលមាន ១៥ សហព័ន្ធ ។ ក្រុមកីឡាគ្រប់ប្រភេទបានរីកចំរើនយ៉ាងឆាប់រហ័ស ។ វិស័យទេសចរណ៍ពិតមែនតែមិនទាន់បានបើកទូលាយ ប៉ុន្តែវិស័យនេះក៏បានដំណើរការឡើងវិញជាបណ្តើរ ។ ប្រាសាទបុរាណនិងរមណីយដ្ឋានប្រវត្តិសាស្ត្រត្រូវបានរៀបចំថែទាំ និង ជួសជុលឡើងវិញ ជាបណ្តើរ ៗ ដោយសហការជាមួយបណ្តាប្រទេសជាមិត្ត ដូចជាសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋប្រជាមានិតប៉ូឡូញជាដើម ។

វិស័យសុខាភិបាល សង្គមកិច្ច ក៏ត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័សដែរ ។ គួបផ្សំនឹងការជួយឧបត្ថម្ភអំពីបណ្តាប្រទេសសង្គមនិយមជាបងប្អូន និងបណ្តាអង្គការមនុស្សធម៌អន្តរជាតិ វិស័យនេះបានធ្វើឲ្យប្រជាជនកម្ពុជាទូទាំងប្រទេសដែលសុទ្ធតែបាក់កម្លាំងក្នុងរបប ប៉ុល ពត អៀងសារី និងមានជំងឺដំកាត់ផ្សេងៗ មានសុខភាពបរិបូរមកវិញក្នុងរយៈពេលមួយយ៉ាងខ្លី ។ នៅគ្រប់មូលដ្ឋាន ជនបទដាច់ស្រយាល សុទ្ធតែមានគ្រូពេទ្យ មានឱសថាល័យ និង មន្ទីរសម្ភព ត្រៀមបំរើប្រជាជនជានិច្ច ។

ទន្ទឹមនឹងការរីកចំរើនវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច វិស័យយោធាក៏បានធំធាត់ហើយពង្រឹងជាលំដាប់ កងទ័ពយើងម្ចាស់ការលើសមរភូមិប្រយុទ្ធ ធានាបានភារកិច្ចការពារខ្សែព្រំដែន ធានាសុវត្ថិភាពសង្គម និង សន្តិសុខជូនប្រជាជន ។ កងទ័ពរបស់យើងបានរីកចំរើន ហើយឈានទៅម្ចាស់ការជំនួសកងទ័ពមិត្តវៀតណាម ដែលមកបំពេញភារកិច្ចអន្តរជាតិជាបន្តបន្ទាប់ ។ ដោយសារ ការរីកចំរើននេះទើបយើងអាចដកកងទ័ពមិត្តតាមដំណាក់កាល ជារៀងរាល់ឆ្នាំ ។ ការដកកងទ័ពវៀតណាមនៅឆ្នាំ ១៩៨៨ គឺជាលើកទី ៧ ជាការដកកងទ័ពក្នុងចំនួនច្រើនជាងលើកមុនៗ ដែលមានចំនួនដល់ទៅ ៥ ម៉ឺននាក់ ព្រមទាំងអគ្គបញ្ជាការ និង ក្រុមជំនាញការកងទ័ពស្ម័គ្រចិត្តវៀតណាមថែមទៀតផង ។

ខាងវិស័យការទូត អត្ថិភាពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា លើឆាកអន្តរជាតិបានលើកកំពស់ ហើយបានធ្វើឲ្យមតិសាធារណៈអន្តរជាតិកាន់តែយកចិត្តទុកដាក់រិតតែខ្លាំង ។ ហើយបានថ្កោលទោសបន ប៉ុល ពត អៀង សារី កាន់តែខ្លាំងធ្វើឲ្យពួកវាកាន់តែឯកោពីមួយថ្ងៃទៅមួយថ្ងៃ ។ គោលនយោបាយបង្រួបបង្រួមជាតិរបស់យើង រិតតែធ្វើអោយយើងបានទទួលជោគជ័យលើឆាកអន្តរជាតិមួយកំរិតថែមទៀត ។

សមិទ្ធផលគ្រប់វិស័យដែលយើងទទួលបានក្នុងរយៈពេល ១០ ឆ្នាំនេះ គឺជាសមិទ្ធផលដែលកើតឡើងដោយសារញើសឈាមរបស់កម្មករ កសិករ បុគ្គលិក កម្មាភិបាល ពោលគឺបក្សទាំងមូល ប្រជាជនទាំងមូល កងទ័ពទាំងមូល ហើយក៏មិនអាចកាត់ផ្តាច់បានពីការជួយឧបត្ថម្ភទាន់ពេលវេលាដោយផ្ទាល់និងមានប្រសិទ្ធិភាពរបស់កងទ័ពស្ម័គ្រចិត្តវៀតណាម របស់ជំនាញការនិងកម្មាភិបាលវៀតណាមបានឡើយ ។

សមមិត្ត ហេង សំរិន អគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្ស ប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានគូសបញ្ជាក់នៅក្នុងសន្ទរកថាថ្លែងក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ៣៧ ថ្ងៃកំណើតបក្សប្រជាជនបដិវត្តកម្ពុជា ថ្ងៃ ២៨-៦-៨៨ ថា “ ប្រសិនបើគ្មានការជួយឧបត្ថម្ភដ៏ស្មោះសរ

ថ្ងៃផ្ការពោរពេញដោយមនោសញ្ចេតនារណ្ណ : និងចិត្តមនុស្សធម៌របស់វៀតណាមនោះគឺមិនអាចមានថ្ងៃ ៧ មករា ១៩៧៩ ជាប្រវត្តិសាស្ត្រទេ មិនអាចមានការរស់ឡើងវិញដ៏អស្ចារ្យនិងបុព្វហេតុដ៏ធំធេងទាំងអស់ដែលត្រូវបានកសាងឡើងវិញនាពេលបច្ចុប្បន្ននេះនៅលើមាតុភូមិយើងទេ ។ »

ពិតមែនតែយើងបានជ័យជំនះយ៉ាងធំធេងគួរជាទីមោទនៈលើគ្រប់វិស័យតែខ្មាំងសត្រូវរបស់យើងមិនព្រមទុកឱ្យប្រជាជនយើងរស់នៅដោយសុខសាន្តទេ ពួកវានៅតែបន្តកាប់សម្លាប់ប្រជាជនយើងតទៅទៀត ។ ដូច្នេះយើងនៅតែសកម្មប្រយុទ្ធតទៅទៀត ដាច់ខាតមិនឱ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញបានឡើយ ។ យើងប្រយុទ្ធដើម្បីការពារខឿនឯករាជ្យជាតិ និងកសាងមាតុភូមិកម្ពុជាសំបូររុងរឿង ។

គោលបំណងដ៏ទទូច និង ជាចាំបាច់បន្ទាន់បំផុតរបស់ប្រជាជនកម្ពុជា គឺសន្តិភាព និងការរស់នៅដោយសុខសាន្តជាអ្នកជិតខាងល្អ ជាមួយប្រជាជននៃប្រទេសជិតខាងក៏ដូចជាមួយប្រជាជននៅលើសាកលលោកទាំងមូល ។

ប្រជាជនទាំងមូល បក្សទាំងមូល កងទ័ពទាំងមូលបានប្តេជ្ញាជាស្រេចថា នឹងផ្តើមយកជ័យជំនះនោះឱ្យបានសំរេចជាស្ថាពរ ដើម្បីសុភមង្គល និងភាពរុងរឿងសំបូរសប្បាយនៃទឹកដីអង្គរដ៏បវរ ។

ជយោ ! សាធារណរដ្ឋប្រជាមានិតកម្ពុជា

KAMPUCHEA TODAY.

The People's Republic of Kampuchea lies in South-East Asia and in the Southern part of Indochina. It covers an area of 181,035 square kilometres with a population of 7,900,000 inhabitants and is divided into 21 provinces and cities, namely the Capital-City of Phnom Penh, the city of Kompong Som and the provinces of Kandal, Prey Veng, Takeo, Kampot, Koh Kong, Kompong Speu, Kompong Chhnang, Pursat, Battambang, Banteay Meanchey, Siem Reap Uddar Meanchey, Preah Vihear, Kompong Thom, Kompong Cham, Kratié, Stung Treng, Rattanakiri and Mondolkiri. Phnom Penh is the capital–city of the People's Republic of Kampuchea. Kompong Som city is its deep-sea port.

The People's Republic of Kampuchea borders the Lao People's Democratic Republic in the North, the Socialist Republic of Vietnam in the East and South-East, the gulf of Thailand in the South-West and the Kingdom of Thailand in the West and North.

The People's Republic of Kampuchea is a land rich of natural resources and has an ancient glorious Culture going back thousand of years. The land formation is made up of three distinct regions : the mountains, the plains and the highlands. The mountainous region stretches all along the Kampuchean-Thai frontier from the North down to the West. The Oural mountain is the tallest, with its peak at 1,800 metres above sea level. This region is abundant in forests and wild animals. Many streams have their sources in these mountains and flow on to the plains below and into the gulf of Thailand.

The highlands occupy the North-Eastern part of the country, stretching from the common borders between the three countries of Kampuchea, Vietnam and Laos, to the South and East of the Mekong river. Most part of this area is covered with fertile volcanic soil. Industrial plantations such as rubber, coffee, fruit trees and forests grow very well here.

The plain area covers the middle of the country and stretches from the Dang Rek mountains in the North-West to the Kampuchean-Vietnamese border in the South-East. This plain area is the food basket for the whole Kampuchean people, because it is rich in fertile farms and rivers, streams and lakes that supply water all year round. The great Tonle Sap Lake is the big source of fish of the People's Republic of Kampuchea. The Mekong, never run dry, is the most important river that flows through Kampuchea from the Northern border to the South, bringing along with it silt and supplying delicious fish.

The hard-working and brave Kampuchean people, comprising of more than 30 ethnics, have been living on this sacred land for many centuries. In their long history, the Kampuchean people had to face up against foreign invaders to defend their territorial integrity to construct their beloved Motherland.

From the 9th to the 14th Century, the Kampuchean people founded famous civilisation, known as the Angkor civilisation, the pride of mankind.

The evidence of that great and prosperous empire are the thousands of ancient temples which, decorated with superb sculptures, are scattered throughout the country.

The Angkor Wat and Bayon Temples which represent the creative talent of the Khmer artists still retain their perfect beauty, both in terms of architecture and decorative art. It is hardly believable that such a marvel could have been built by human beings.

But due to the greedy, bellicose, arrogant feudalists, who slighted the enemies, from the end of the 14th century, the glorious civilisation started gradually to fade away and came to an almost complete extinction. For the next 600 years, as the result of wars for the throne fought between rival feudal families, the Kampuchean people knew only sufferings, separations and depredations.

The internal feud had so badly degraded the country that later the colonialists and imperialists took turns in imposing their yokes for hundreds of years.

During these hundreds of years spent under the oppression and exploitation of foreign colonialist powers, the people stood up and put up brave struggles to wrest back their lost freedom and independence.

On April 17th, 1975, the Kampuchean people shattered the US backed Khmer Republic regime. Everyone then expected to be able to live in peace, freedom, happiness and to contribute to the construction work to heal the deep wounds caused by the destructive wars.

But all those hopes were dashed in just a few minutes. The opportunist clique of Pol Pot — Ieng Sary — Khieu Samphan took advantage of and misappropriated the Kampuchean people's victory. They further shattered Kampuchea, already reduced by war, into ashes. The whole Kampuchean people became slaves and convicts under death sentence. The whole social and material infrastructure were completely destroyed. In no time at all, every thing that was built by the Kampuchean people during the last thousand years was torn to pieces. Schools, markets, money, religions, pagodas, hospitals, factories, cities and towns were either shut down or abolished.

The clique of Pol Pot, Ieng Sary and Khieu Samphan plunged the whole Kampuchean people into the abyss of genocide, unequalled by its brutality and unprecedented in the history of mankind. Kampuchea became a

horrifying killing field. Within a matter of only 3 years, 8 months and 20 days, they indiscriminatedly massacred more than 3 millions people. About 90% of intellectuals, physicians, engineers, artists, professors, teachers and technicians, together with their families, were thus put to death.

Fine arts, culture and literature, as well as thousands of ancient books, temples and statues which represent the National soul were also shattered.

Conscious of the approaching danger of national extinction patriots who had escaped the massacre and unwalled prison, came together to found the National United Front for the Salvation of Kampuchea on December 2nd, 1978 to liberate the country from genocide. Under the Front's just leadership together with the sincere and timely assistance of the Vietnamese Party and people and army of volunteers, the Kampuchean people all over stood up as a single man to smash the genocidal regime of Pol Pot, Ieng Sary and Khieu Samphan and scored final victory on January 7th, 1979.

The historic day of January 7th, 1979 will always be remembered by every Kampuchean as their day of rebirth.

The nightmare of genocide was over and with it the bloodthirsty monsters had gone. The bright sunshine of New Day once again illuminates the beloved Angkor Land ; new hopes return to the heart of every Kampuchean.

But the consequences of the vicious genocidal Pol Pot regime are indeed very heavy in every way for our revolutionary authorities. The victory won by the Revolution of Kampuchea has brought our people face to face with numerous problems to be solved without delay.

After the January 7th, 1979 liberation, every single soul was physically exhausted, psychologically worn out and sick, but bare hands, everyone actively took part in the defence of revolutionary gains, of national independence and in the reconstruction of the country. The whole social structure has to start all over again from scratch.

The People's Revolutionary Party of Kampuchea, a genuine Marxist–Leninist Party was immediately reestablished. The ties of Friendship and Solidarity between Kampuchea–Vietnam–Laos and the Fraternal Socialist Countries have been strengthened and expanded.

Under the clear-sighted leadership of the People's Revolutionary Party of Kampuchea, with the whole hearted assistance of the Fraternal Socialist Countries, such as the Socialist Republic of Vietnam, the Lao People's Democratic Republic, the Union of Soviet Socialist Republics and other Fraternal Socialist Countries as well as of the International Humanitarian Organisations, everything has started to come back to life again and has made remarkable progress. Encouraged by the speed with which the political, economic and diplomatic life has evolved, the 5th Party Congress set out new tasks and objectives for the Kampuchean Revolution. That has been a new turning point leading to new developments preparing the ground for transitional period proceeding towards socialism.

During the past 10 years, the Kampuchean Revolutionary Authorities have not only administered the whole of Kampuchea, but Local Authorities have also been consolidated.

All State Institutions function normally and have been improving in every way.

Workers, farmers, office workers and cadres perform their tasks in solidarity around the Party.

As a result, their endeavour has rendered commendable achievements.

Farmland have been restored and expanded from 800,000 ha. in 1979 to more than 2,000,000 ha. in 1988. Besides rice production, attention has been paid to promote husbandry and subsidiary crops, such as corn, beans, sesame, pepper and other industrial crops such as tobacco, jute and cotton.

Rubber production is one of the state's main economic objectives. We have recovered and exploited the existing rubber plantations from 5,000 ha. to 43,000 ha. in 1988 with an output in dry latex in the same period from 1,300 tons to 24,900 tons.

Timber production, another important objective of the state economy, has made a remarkable progress. In 1980, we produced only 700 m^3 of timber, but by the end of 1987, we produced 157,441 m^3. While timber exploitation is under way, priority is given to the preservation of the existing forests and to reforestration. In 1988, 650 ha. have been planted.

Fish production is another main economic objective. In 1980, fresh water fish catch was only 18,400 tons, but in 1987, it increased to 62,154 tons, whereas sea fish catch in the same period, increased from 1,200 tons to 9,884 tons.

With regard to industry and handicraft, almost all small and large factories, damaged by war, have been repaired and put back into operation. Now over 50 state owner's factories are working normally. Besides, more than one thousand handicraft workshops have been set up by collective solidarity groups to produce various consumers' goods and production tools to meet the people's daily need.

Transports by road, waterway, railway and by air for passengers and goods have been put to the service of the public throughout the country. Kompong Som sea port, during Pol Pot's regime, received only ships from Beijing. It is now opened to all foreign ships.

On the same way, only one air route existed between Phnom Penh and Beijing. Now the Pochentong International Airport has traffic links with airlines of the Fraternal Socialist Countries.

Railway linking Phnom Penh–Kompong Som and Phnom Penh–Battambang are quite busy carrying thousands of tons of goods every day. The Kampuchea - Soviet Friendship Satellite communication Station " Bayon", recently put into operation, enables the Kampuchean people to communicate by telephone with all countries of the world.

Education, completely abolished during Pol Pot, Ieng Sary and Khieu Samphan's genocidal regime, has been rapidly restored. The first historical school reopening was presided over by Comrade Heng Samrin on September 24th, 1979. A complete new educational system has been established to include kindergarten, primary, secondary, higher and specialised education. In the 1987–88 school year, about 1,700,000 pupils and students attend schools of all grades and among them 59,621 children are in kindergartens. So far 1,002,228 people have passed literacy exams and 183,994 persons have been attending complementary classes of various grades. Every year about 1,000 students have been sent abroad for higher education. So far, six establishments of higher education specialise in 30 courses, 26 technical schools cover 61 courses and 29 other vocational training schools cover 37 courses. We have a corps of more than 55,000 teachers spread all over the country.

Appreciable progress have been made in the maintenance of national cultural heritage and the care and the training of artists. In 10 years, 42 ensembles with 1,260 professional artists and 2,950 ensembles of amateur artists have been formed. Large theatres have been built. As the most popular pastime, movies have been always on the show and mobile cinemas brought to every corner of the country. Besides the imported films, efforts have been made to produce films by ourselves. Schools of Fine Arts and of sports and physical education have been training primary and secondary pupils and prepared for higher training.

The Khmer olympic commission have been reorganised to include 15 federations. Sport teams of all disciplines have rapidly grown up. Although tourism is not yet fully operational, but it has gradually returned to life. Restoration and maintenance of historical temples and monuments have gradually been done in cooperation with friendly countries, such as the Republic of India and the People's Republic of Poland.

Health and social services have also been rapidly restored, and with the assistance of Fraternal Socialist Countries and International Humanitarian Organisa - tions, in a short period, health has returned to the Kampuchean people after being ill from overwork under Pol Pot – Ieng Sary regime. Even the remote rural areas now have health centers, pharmacies and maternity centers at the service of the public.

